អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី ០៣ មីនា ២០០៩

ថ្ងៃនេះសហចៅក្រមស៊ើបអង្កេតបានចេញដីកាមួយ សម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ( http://www.eccc.gov.kh/english/cabinet/courtDoc/248/D138_EN.pdf ) បន្ទាប់ពីមានការផ្សព្វផ្សាយដោយក្រុមមេធាវីការពារក្តី នូវឯកសារសម្ងាត់ នៅលើ គេហទំព័ររបស់ពួកគេ។

ជាការឆ្លើយតបទៅនឹងការរំលោភបំពានដ៏ច្បាស់លាស់និងជាដដែលៗ លើការណែនាំរបស់សហចៅក្រមស៊ើបអង្កេតនេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាឲ្យក្រុមមេធាវីការពារក្តីធ្វើការ បញ្ឈប់ជាបន្ទាន់នូវការផ្សព្វផ្សាយរាល់ឯកសារដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ លើកលែងតែឯកសារ ដែលមានផ្សព្វផ្សាយរួចហើយនៅលើគេហទំព័ររបស់ អ.វ.ត.ក. និង ធ្វើការដកឯកសារទាំងនោះចេញពីគេហទំព័ររបស់ក្រុមមេធាវីការពារក្តីនោះវិញក្នុងរយៈពេល ៤៨ ម៉ោង បើមិនដូច្នោះទេ នឹងទទួលរងទណ្ឌកម្ម ដោយការប្រព្រឹត្តបទល្មើសថ្មីមួយទៀត។ ក្នុងពេលជាមួយគ្នានោះដែរ សហចៅក្រមស៊ើបអង្កេត ក៏បានបញ្ជូនអត្ថបទថតចម្លងនៃដីកាខាងលើទៅអង្គភាពវិជ្ជាជីវៈដែលពាក់ព័ន្ធ រួមទាំងអង្គភាពគាំពារការការពារក្តីដើម្បីធ្វើការពិចារណាលើវិធានការដែលត្រូវអនុវត្តបន្ត។

សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយយោងលើវិធាន ៥៦.១ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ដែលចែងថា *"ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជា សាធារណៈឡើយ។ បុគ្គលទាំងអស់ ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់។"* វិធាននេះត្រូវអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់ ដែលចូលរួមក្នុងកិច្ចស៊ើបសួរ ជាពិសេសមេធាវីរបស់ ភាគីទាំងឡាយ និងលើគ្រប់ប្រភេទនៃភស្តុតាងទាំងអស់។ វិធានផ្ទៃក្នុង (វិធាន ៥៦.២) បញ្ជាក់បន្ថែមទៀតថា គឺមានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការសម្រេចផ្សព្វផ្សាយ នូវព័ត៌មានដែលទាក់ទងនឹងកិច្ចស៊ើបសួរដែលកំពុងតែដំណើរការ ឬធ្វើការអនុញ្ញាតឲ្យប្រព័ន្ធផ្សព្វ ផ្សាយណាមួយ ឬតតិយជនណាមួយទទួលបាននូវព័ត៌មានទាក់ទងនឹងកិច្ចស៊ើបសួរ។ ក្នុងករណីដែល មិនគោរពលក្ខខណ្ឌនានា ដែលកំណត់ដោយចៅក្រម វិធាន ៣៥ ដល់ ៣៨ នឹងត្រូវយកមកអនុវត្ត។

សហចៅក្រមស៊ើបអង្កេតសូមធ្វើការពន្យល់បកស្រាយអំពីហេតុផលនានា ដែលនាំឱ្យឈាន ទៅដល់ការចេញសេចក្តីសម្រេចនេះ។

មុននឹងមានការរៀបចំសវនាការជំនុំជម្រះជាសាធារណៈ គ្រប់នីតិវិធិតុលាការទាំងអស់ តែង តែចាប់ផ្តើមដោយដំណាក់កាលនៃការស៊ើបអង្កេត ដែលមានរយៈពេលវែង ឬខ្លីអាស្រ័យតាមទំហំ នៃការងារនេះ។ ចរិតលក្ខណៈសម្ងាត់នៃដំណាក់កាលនេះ មានសារៈសំខាន់ខ្លាំងណាស់ចំពោះ គុណភាពនៃដំណើរការតុលាការ ជាពិសេសដើម្បីធានាការការពារជីវិតឯកជនរបស់បុគ្គល ដែលមាន ឈ្មោះនៅក្នុងសំណុំរឿង និងការធានាអំពីគោលការណ៍សច្ចាធារណ៍និរទោស និងក៏ដើម្បីធានាប្រសិទ្ធិ ភាពនៃកិច្ចស៊ើបសួរផងដែរ។

សហចៅក្រមស៊ើបអង្កេត ដឹងថា ដំណាក់កាលនៃកិច្ចស៊ើបសួរជាសម្ងាត់ នឹងមិន អនុញ្ញាតឱ្យអ្នកសង្កេតការណ៍ខាងក្រៅតុលាការ អាចមានលទ្ធភាពយល់ដឹងឥតខ្ចោះអំពីដំណើរការទៅ មុខនៃនីតិវិធីនោះទេ។ ហេតុដូច្នេះហើយបានជាសហចៅក្រមស៊ើបអង្កេតព្យាយាមកំរិតថេរៈវេលានៃ កិច្ចស៊ើបសួរឱ្យខ្លីបំផុតតាម ដែលអាចធ្វើទៅបាន។ សហចៅក្រមស៊ើបអង្កេត រំលឹកថា នៅក្នុងករណី ឌុច កិច្ចស៊ើបសួរមានរយៈពេលមិនលើសពីមួយឆ្នាំទេ (ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលមាន បញ្ជាក់យ៉ាងលំអិតអំពីបទចោទនានា ត្រូវបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី ០៨ សីហា ឆ្នាំ ២០០៨) ដែលនេះមិនអាចត្រូវបានចាត់ទុកថាយូរហួសហេតុពេកទេ បើពិនិត្យទៅលើភាពស្មុគស្មាញនៃសំណុំរឿង។ ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត កំពុងព្យាយាមអស់លទ្ធភាព ដើម្បីឱ្យកិច្ចស៊ើបសួរ បច្ចុប្បន្ននៅក្នុងសំណុំរឿងទី ០២ ដំណើរការទៅដោយមិនមានភាពយឺតយ៉ាវ។

ដើម្បីបង្កើន តាមដែលអាចធ្វើទៅបាន នូវការយល់ដឹងជាសាធារណៈ សហចៅក្រមស៊ើប អង្កេត រំលឹកថា ជារៀងរាល់ខែ គេអាចរកបានព្រឹត្តិប័ត្រព័ត៌មាន ដែលបរិយាយជាសង្ខេបនូវសកម្ម ភាពរបស់អង្គភាពផ្សេងៗនៃ អ.វ.ត.ក. នៅលើគេហទំព័ររបស់ អ.វ.ត.ក. ដែលក្នុងនោះព័ត៌មានរបស់ ការិយាល័យសហចៅក្រម ស៊ើបអង្កេតមាននៅក្នុង៖ (http://www.eccc.gov.kh/english/publications.courtReport.aspx) ។ បន្ថែមលើសនេះ ទៀត ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃគោលការណ៍ទាំងអស់ខាងលើ សហចៅក្រមស៊ើបអង្កេតនឹង ធ្វើការផ្សព្វផ្សាយ ឱ្យបានច្រើនជាងមុនអំពីសកម្មភាពនានារបស់ខ្លួន និងធ្វើការបោះផ្សាយឯកសារ ដែលទាក់ទងនឹងកិច្ចស៊ើបសួរក្នុងចំនួនច្រើនជាងមុនផងដែរ។

ជាចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេត សូមធ្វើការរំលឹកថា ទោះបីជារាល់សេចក្តីសម្រេច របស់តុលាការ អាចត្រូវបានជំទាស់ដោយសារបណ្តឹងឧបាស្រ័យក៏ដោយ ក៏សេចក្តីសម្រេចទាំងនេះ មិនអាចត្រូវបានមិនគោរព ដោយមិនអើពើនោះដែរ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh